# គំរោងសង្ខេប

## ឈ្មោះគំរោង : គាំទ្រអភិបាលកិច្ចល្អនៅមូលដ្ឋាន

## I. បរិបទ :

### ក. ហេតុផល

រៀបរាប់សង្ខេបពីស្ថានការណ៍ទាក់ទិននឹងសំណើសុំថវិកា ដើម្បីដោះស្រាយប្រភេទបញ្ហា/រឿងរ៉ាវណាមួយក្នុងតំបន់រងឥទ្ធិពល ដោយពន្យល់ពីសារៈសំខាន់នៃគំរោង (យ៉ាងវែងបំផុត : មួយកថាខណ្ឌ)

**១. តើប្រភេទបញ្ហាអ្វី និងមានទំហំប៉ុណ្ណា?**

នៅឆ្នាំ២០០២ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តន៏កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់មូលដ្ឋាន ដោយរៀបចំអោយមានការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីអោយអនុវត្តអភិបាលកិច្ចល្អនៅមូលដ្ឋាន។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តន៏របស់ ក្រុមប្រឹក្សានៅមិនបានបំពេញទៅ នឹងតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនឡើយ មិនឆ្លើយតមទៅតាមគោលការណ៏អភិបាលកិច្ច ជាពិសេសគោលការណ៏តម្លាភាព និងការទទួលខុសត្រូវសង្គម។

**២. ទីតាំង/តំបន់រងឥទ្ធិពល**

២៣ឃុំ ក្នុងស្រុកក្រគរ ស្រុកភ្នំក្រវាញ និងស្រុកវាលវែង ខេត្តពោធិ៏សាត់ ប្រទេសកម្ពុជា។

**៣. ហេតុអ្វីបានជាសំខាន់?**

- ខ្វះយន្តការក្នុងការពង្រឹងការអនុវត្ត តម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋាន។
- ការប្រើប្រាស់ថវិការមិនចំទិសដៅដោយគ្មានតម្លាភាព និងគណនេយ្យភាព ធ្វើអោយការអភិវឌ្ឍន៍នៅមូលដ្ឋាន មិនបានឆ្លើយតបទាន់ពេលវេលា និងមិនមាននិរន្តរភាព។
- ធ្វើអោយកម្មវិធីកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋាភិបាលមិនអាចដល់ គោលដៅដោយខ្វះការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។

**៤. តើបញ្ហាកើតឡើងដោយរបៀបណា (ឬសគល់នៃបញ្ហា)**

១. ការអនុវត្តន៏យន្តការ ពង្រឹងការអនុ វត្តតម្លាភាព និងគណនេយ្យភាពទន់ខ្សោយ

២. .គ្មានអ្នកត្រួតពិនិត្យ ការទទួលខុសត្រូវសង្គមរបស់ក្រុមប្រឹក្សាឃុំ

៣. ខ្វះការចូលរួមពីប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន

**៥. អ្នកទទួលផលគោលដៅ:** ប្រជាពលរដ្ឋឃុំគោលដៅ (ជនក្រីក្រ ស្ត្រីមេម៉ាយ ចាស់ជរា និងជនជាតិភាគតិច) ។

## II. គំរោង

| **សង្ខេបអំពីគំរោង** | **ការពិពណ៌នាអំពីតក្កភាពអន្តរាគមន៍** |
|---|---|
| **ក.គោលដៅ** | **តើអ្នកចង់ឃើញការផ្លាស់ប្តូរអ្វីនៅរយៈពេលវែង ទាក់ទងនឹងបរិបទ (ឧទាហរណ៍ អភិបាលកិច្ចល្អឬវិមជ្ឈការនិងវិសហមជ្ឈការ ឬការទទួលខុសត្រូវសង្គម) ក្រោយពីគំរោងបានបញ្ចប់?**<br><br>បង្កើនការចូលរួមរបស់ប្រជាជនដើម្បីលើកកំពស់អភិបាលកិច្ចល្អក្នុងមូលដ្ឋាន |
| **ខ.ទិសដៅ** | **តើអ្នកចង់ឃើញការផ្លាស់ប្តូរអ្វីនៅរយៈពេលមធ្យម (ឬការសំរេចជាក់លាក់ដែលគំរោងនឹងធ្វើការដោះស្រាយបញ្ហា/រឿងរ៉ាវ ដូចដែលបានបង្ហាញនៅក្នុងមាតិកា "បរិបទ") ដើម្បីសំរេចគោលដៅខាងលើនៅពេលដែលគំរោងកំពុងដំណើរនិងនៅពេលដែលគំរោងបញ្ចប់?**<br>(ទិសដៅលើសពីពីរ នឹងលំបាកធ្វើការវាស់វែង)<br>ក្រុមប្រឹក្សាឃុំចំនួន២៣ឃុំ ក្នុងស្រុកក្រគរ ស្រុកវាលវែង ស្រុកក្រវ៉ាញ ក្នុងខេត្តពោធិសាត់ អាចអនុវត្តការងារប្រកបដោយតម្លាភាព និងគណនេយ្យភាពនៅឆ្នាំ២០១០ ។ |
| **គ.លទ្ធផល** | **តើលទ្ធផលចំបង (ឬការផ្លាស់ប្តូររយៈពេលមធ្យម) អ្វីខ្លះ ដែលនាំឱ្យសំរេចគោលដៅខាងលើ?(ចូរចងចាំថា : លទ្ធផលនៃការធ្វើសកម្មភាពកសាងសមត្ថភាព ដើម្បីផ្ទេរចំណេះដឹងនិងជំនាញពីវគ្គបណ្តុះបណ្តាលនៃ "ការទទួលខុសត្រូវសង្គម" ដល់អ្នកដទៃ ពុំគិតបញ្ចូលជាផ្នែកនៃលទ្ធផលចំបងដែលនាំឱ្យសំរេចទិសដៅគំរោងទេ ។)** |

| | |
|---|---|
| | ១.១. ការអនុវត្តយន្តការនៃការត្រួតពិនិត្យតម្លាភាព និងគណនេយ្យភាព ត្រូវបានពង្រឹង និងអនុវត្តន៍ ។<br>១.២. ការងារក្រុមប្រឹក្សាឃុំត្រូវបានត្រួតពិនិត្យដោយក្រុមត្រួតពិនិត្យសហគមន៍<br>១.៣. ការចូលរួមរបស់ប្រជាពលរដ្ឋមានការកើនឡើង |
| **ឃ.សកម្មភាព** | **តើសកម្មភាពអ្វីខ្លះ ដែលត្រូវធ្វើដើម្បីសំរេចលទ្ធផលចំបងខាងលើ**<br>*១.១. ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ អំពីការទទួលខុសត្រូវសង្គម វិមជ្ឈការ និងវិសហមជ្ឈការ*<br>*១.២. រៀបចំបណ្តាញប្រជុំជាមួយគណៈកម្មការគណនេយ្យភាពខេត្ត*<br>*១.៣. អង្គការសង្គមស៊ីវិល និងតំណាងប្រជាពលរដ្ឋចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំក្នុងការរៀបចំផែនការថវិកា*<br>*១.៤. ពង្រឹងយន្តការ ការផ្តល់ពត៌មានត្រឡប់ពីប្រជាពលរដ្ឋ (ការតវ៉ា វេទិការសាធារណៈ គណនេយ្យភាពតាមភូមិ)* |
| | *២.១. ផ្សព្វផ្សាយពីផលប្រយោជន៍នៃការទទួលខុសត្រូវសង្គមតាមភូមិ*<br>*២.២. បង្កើតក្រុមត្រួតពិនិត្យក្នុងមូលដ្ឋាន*<br>*២.៣. ពង្រឹងសម្ថភាពក្រុមត្រួតពិនិត្យ*<br>*២.៤. សម្របសម្រួល ចងក្រងបណ្តាញក្រុមត្រួតពិនិត្យសហគមន៍មូលដ្ឋានដែលមានស្រាប់*<br>*២.៥. រៀបចំប្រជុំប្រចាំខែ ត្រីមាស ឆ្នាំ* |

| | |
|---|---|
| | ២.៦. តាមដានត្រួតពិនិត្យការអនុវត្តនីតួនាទីរបស់ក្រុមប្រឹក្សាឃុំ<br>និងធ្វើរបាយការរបស់ក្រុមត្រួតពិនិត្យសហគមន៍ |
| | ៣.១. ប្រជុំផ្សព្វផ្សាយពីសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអនុវត្តនីវិមជ្ឈការ និងវិសហមជ្ឈការតាមភូមិ<br><br>៣.២. ក្រុមប្រឹក្សាឃុំរៀបចំវេទិកាសាធារណៈ<br><br>៣.៣. ក្រុមប្រឹក្សាឃុំរៀបចំការប្រជុំទៀងទាត់នៅតាមភូមិដើម្បីដោះស្រាយបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋ<br><br>៣.៤. ពង្រើកប្រព័ន្ធផ្សាយពតិមានពីក្រុមប្រឹក្សាឃុំដល់ប្រជាពលរដ្ឋអោយបានទូលំទូលាយ និងមានប្រសិទ្ធភាព (មេក្រូ ក្តារពតិមាន ផ្ទាំងរូបភាព បុណ្យទាន និងកម្មវិធីសង្គមផ្សេងៗ) |

## III. ផែនការការងារ

| សកម្មភាព | ឆ្នាំ2009 (គិតជាខែ) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១.១-ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ អំពីការទទួលខុសត្រូវសង្គម<br><br>វិមជ្ឈការ និងវិសហមជ្ឈការ<br><br>១.២-<br>រៀបចំបណ្តាញប្រជុំជាមួយគណៈកម្មការគណនេយ្យភាព | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| *ខេត្ត*<br>*១.៣អង្គការសង្គមស៊ីវិលចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំក្នុងការ រៀបចំផែនការថវិកា*<br>*ពង្រឹងយន្តការ ការផ្តល់ព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ (ការតវ៉ា វេទិកាសាធារណៈ គណនេយ្យភាពតាមភូមិ)* | | | | | | | | | | | | |
| **សកម្មភាព១,១,២**<br>បង្ហាត់បង្ហាញសមាជិកគណៈកម្មការបង្កើតថ្មី ពីរបៀបភ្ជាប់ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំនិងប្រជាពលរដ្ឋ ក្នុងឃុំ | | | ↔ | ↔ | | | | | | | | |
| **សកម្មភាព១,២,១**<br>បង្ហាត់បង្ហាញសមាជិកគណៈកម្មការបង្កើតថ្មី ដើម្បីបង្ហាត់បង្ហាញទៅក្រុមប្រឹក្សាឃុំ អំពីវិធីចុះធ្វើសកម្មភាពពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងឃុំដើម្បីកសាងផែនការវិនិយោគឃុំ | | | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | | | |
| **សកម្មភាព១,២,២**<br>កសាងផែនការវិនិយោគឃុំដោយមានការចូលរួមរបស់ប្រជាពលរដ្ឋជាមូលដ្ឋាន | | | | | | ↔ | ↔ | ↔ | ↔ | ↔ | | |

## ៤. ក្របខណ្ឌការងារអន្តភាព

**តើអ្នកនឹងសហការជាមួយនរណា និងដោយរបៀបណា?**

**១. នៅក្នុងគំរោងរបស់អ្នក?**

- ក្រុមសំរបសំរួលថ្នាក់ស្រុក : ដើម្បីមានឥទ្ធិពលលើក្រុមប្រឹក្សាឃុំក្នុងការសហការណ៍ជាមួយនឹងគណៈកម្មការដែលបានបង្កើត ហើយជួយជំរុញបន្ថែម ឱ្យសំរេចទិសដៅនៃគំរោង ។
- ប្រជាពលរដ្ឋក្នុងឃុំ និងអង្គការសមាគមមូលដ្ឋាន : ដើម្បីជំរុញឱ្យគាត់ចូលរួម នៅក្នុងអន្តរាគមន៍សំរេចទិសដៅនៃគំរោង

**២. នៅកំរិតថ្នាក់ខេត្ត/ជាតិ?**

អង្គភាពរដ្ឋបាលមូលដ្ឋានថ្នាក់ខេត្តៈ ដើម្បីមានឥទ្ធិពលលើក្រុមសំរបសំរួលថ្នាក់ស្រុកនិងអភិបាលស្រុកលើការសហការណ៍ជាមួយនឹងគំរោងនិងផ្នែកសហការណ៍ដទៃទៀត ។

## ៥, ឧបករណ៍ប្រើប្រាស់

តើឧបករណ៍ទទួលខុសត្រូវសង្គមអ្វី ដែលគំរោងនឹងប្រើប្រាស់ តើប្រើប្រាស់ដោយរបៀបណា?

- ការធ្វើផែនការដោយមានការចូលរួមៈ ដើម្បីបង្កើតផែនការវិនិយោគឃុំ
- ធ្វើសវនកម្មសង្គម Social Audit
- ការប៉ាន់ប្រមាណតំរូវការ
- គណៈកម្មការតាមដានសហគមន៍(Community Monitoring Committee)

## ៦. គំរោងថវិកា

| សកម្មភាព/ធនធាន | ឯកតា | ចំនួន | តំលៃឯកតា | តំលៃសរុប |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| **សកម្មភាព១.១.១**<br>បង្កើតគណៈកម្មការមួយ<br>ធនធាន:<br>ក. បោះពុម្ពឯកសារពតិមាន<br>ខ. សាំង<br>គ................ | ច្បាប់<br>លីត្រ | 50<br>10 | 0.50$<br>1.20$ | 0.50$<br>1.20$ |
| **សកម្មភាព១.១.២**<br>បង្ហាត់បង្ហាញសមាជិកគណៈកម្មការដែលបង្កើតថ្មី<br>ធនធាន:<br>ក. | | | | |
| **សកម្មភាព១.២.១**<br>បង្ហាត់បង្ហាញសមាជិកគណៈកម្មការដែលបង្កើតថ្មីដើម្បី<br>បង្ហាត់បង្ហាញក្រុមប្រឹក្សាឃុំ<br>ធនធាន:<br>ក. | | | | |
| **សកម្មភាព១.២.២**<br>កសាងផែនការវិនិយោគឃុំ<br>ធនធាន:<br>ក. | | | | |